**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៦៣ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំសម្រាប់បំពេញការកិច្ចគ្រប់គ្រងពូជដំណាំនិងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី២

## ឯកសណ្ឋាននិងសញ្ញាសម្គាល់

**មាត្រា២ .-**

ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ដូចខាងក្រោម៖

- ឯកសណ្ឋាន រួមមានសម្លៀកបំពាក់ មួក ខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើង
- សញ្ញាសម្គាល់ រួមមានស្លាកសញ្ញាសម្គាល់ភ្នាក់ងារអធិការកិច្ចពូជដំណាំ ស្លាកសម្គាល់ឈ្មោះនិងឋានៈរបស់មន្ត្រីជាភ្នាក់ងារអធិការកិច្ចពូជដំណាំ ព្រមទាំងសញ្ញាសក្តិដែលជាសញ្ញាសម្គាល់ឋានៈរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ។

## ផ្នែកទី១

## ឯកសណ្ឋាន

**មាត្រា៣ .-**

សម្លៀកបំពាក់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់យកប្រភេទសាច់ក្រណាត់ពណ៌បៃតងចាស់ ដូចខាងក្រោម៖

ក- ចំពោះបុរស

១- អាវមាន២(ពីរ)ប្រភេទ៖

- អាវដៃវែងសម្រាប់ពិធីការ
- អាវដៃវែងឬអាវដៃខ្លីសម្រាប់ការងារអធិការកិច្ច។

**១.១- អាវដៃវែងសម្រាប់ពិធីការ**ត្រូវបានកំណត់ជា២(ពីរ)ថ្នាក់៖

- **ថ្នាក់អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋាន** : មានទម្រង់ជាអាវធំដៃវែង កាត់រាងវ៉ារីមានចែកខ្នងខាងក្រោមមួយចំកណ្តាល កបើកធំពីរសន្លឹក មានប៊ូលស្មានៅសងខាងភ្ជាប់ដោយខ្សែរពណ៌ដូចអាវ នៅផ្នែកខាងមុខនៃអាវមានដាក់ខ្សែរូបព្រះរាជសង្ហារពណ៌មាស

មានហោប៉ៅចំនួនបួន ហោប៉ៅពីរខាងលើដេរជាលក្ខណៈប៉ះបត់ពីរផ្នត់ចំកណ្ដាលមានគម្របរាងស្លឹកពោធិ៍ភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស ហោប៉ៅពីរខាងក្រោមដេរជាលក្ខណៈមាត់កាត់មានគម្របរាងចតុកោណកែងដែលមានចុងសងខាងរាងទាល និងនៅផ្នែកចំហៀងនៃចុងដៃអាវមានភ្ជាប់ដោយឡេវបញ្ឆោតរូបព្រះរាជសង្ហារពណ៌មាសចំនួនបីគ្រាប់។

- **ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធាននិងអនុប្រធានមន្ទីរ ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ និងមន្ត្រី** : មានទម្រង់លក្ខណៈដូចអាវដៃវែងសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋានដែរ ប៉ុន្តែខុសគ្នាត្រង់ឡេវអាវរូបព្រះរាជសង្ហារមានពណ៌ប្រាក់។

**១.២- អាវដៃវែងឬអាវដៃខ្លីសម្រាប់ការងារអធិការកិច្ចត្រូវបានកំណត់ជា២(ពីរ)ថ្នាក់៖**

- **ថ្នាក់អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋាន** : មានទម្រង់ជាអាវសាហារីយែនដៃវែងឬដៃខ្លីមានកបើកពីរសន្លឹក មានប៉ូលស្មានៅសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវមានផែកខ្នងខាងក្រោមមួយចំកណ្ដាល និងមានហោប៉ៅបួន ដែលហោប៉ៅពីរខាងលើដេរប៉ះបត់ផ្នត់កណ្ដាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្ដាលនិងមានគម្របរាងចតុកោណកែងដែលមានចុងសងខាងរាងទាល ហើយឡេវអាវនិងឡេវហោប៉ៅមានរូបព្រះរាជសង្ហារពណ៌មាស។
- **ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធាននិងអនុប្រធានមន្ទីរ ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ និងមន្ត្រី** : មានទម្រង់លក្ខណៈដូចអាវដៃវែងឬអាវដៃខ្លីសម្រាប់ថ្នាក់អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋានដែរ ប៉ុន្តែខុសគ្នាត្រង់ឡេវអាវនិងឡេវហោប៉ៅមានរូបព្រះរាជសង្ហារពណ៌ប្រាក់។

២- **ខោជើងវែង**មាន១(មួយ)ប្រភេទសម្រាប់ភ្នាក់ងារអធិការកិច្ចពូជដំណាំគ្រប់ថ្នាក់។

ខោជើងវែងផលិតពីសាច់ក្រណាត់និងមានពណ៌ដូចអាវ មានចង្កេះដេរតថ្មេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅចំហៀងពីរដេរបង្កប់តាមថ្នេរ និងមានហោប៉ៅក្រោយពីរដេរបង្កប់ដែលមានគម្របរាងស្លឹកពោធិ៍។

**ខ- ចំពោះនារី**

១- អាវមានពីរប្រភេទដូចបុរសដែរ គឺអាវដៃវែងសម្រាប់ពិធីការនិងអាវដៃវែងឬអាវដៃខ្លីសម្រាប់ការងារអធិការកិច្ច។ អាវទាំងពីរប្រភេទសម្រាប់នារីមានទម្រង់លក្ខណៈដូចអាវសម្រាប់បុរសដែរ ប៉ុន្តែខុសគ្នាត្រង់អាវនារីមានជីបរាងនិងមានលក្ខណៈខុសគ្នាតាមប្រភេទដូចអាវបុរសដែរ។

២- ខោជើងវែងមានទម្រង់លក្ខណៈដូចខោជើងវែងសម្រាប់បុរសដែរ ប៉ុន្តែមិនមានហោប៉ៅក្រោយឡើយ។

៣- សំពត់ផលិតពីសាច់ក្រណាត់និងមានពណ៌ដូចអាវ មានរាងបំពង់ តចង្កេះ សម្រុងចុះក្រោមដល់ពាក់កណ្ដាលស្មងជើង ផែកខាងក្រោយ និងមានរូតនៅចំហៀង។

គំរូសម្លៀកបំពាក់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

មួកសម្រាប់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ជា៣(បី)ប្រភេទ៖

- មួកកាស្កេតសម្រាប់ពិធីការចំពោះបុរស
- មួកសំបុកសម្រាប់ពិធីការចំពោះនារី
- មួកកន្ទឹបសម្រាប់ការងារអធិការកិច្ចចំពោះបុរសនិងនារី។

១- មួកកាស្កេតផលិតពីសាច់ក្រណាត់និងមានពណ៌ដូចខោនិងអាវដែរ មានក្បាំងពណ៌ខ្មៅនិងមានកណ្តាប់វ័ណ្ឌប៉ានជុំវិញរង្វង់ជើងមួកពណ៌បៃតងខ្ចី ហើយផ្នែកខាងលើកណ្តាប់វ័ណ្ឌនៅចំកណ្តាលផ្នែកខាងមុខមួកមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។ ផ្នែកខាងមុខក្រោមកណ្តាប់វ័ណ្ឌមានកម្រងខ្សែសយពណ៌មាសនិងចុងខ្សែទាំងសងខាងមានភ្ជាប់ឡេវត្រារូបព្រះរាជសង្ហារពណ៌មាសម្ខាងមួយ។ នៅត្រង់កណ្តាប់វ័ណ្ឌផ្នែកខាងមុខរចនាដោយក្បាច់ប៉ានរូបកណ្តាប់ស្រូវបញ្ឈរកម្ពស់៣៥មិល្លីម៉ែត្រ និងអមសងខាងដោយសន្លឹកភ្ញីទេសពណ៌មាសទំហំទទឹង២០មិល្លីម៉ែត្រ។ ក្បាំងមួកមានពណ៌ខ្មៅដែលផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីមានប្រវែងខុសគ្នាឆ្ពោះទៅរកជើងមួក។

មួកកាស្កេតត្រូវបានកំណត់ជា៥(ប្រាំ)ថ្នាក់ ដូចខាងក្រោម៖

១.១- **ថ្នាក់អគ្គនាយក** : ក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងដល់ជើងមួកនិងគែមរបស់ក្បាំងមួកមានវ័ណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

១.២- **ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន** : មានទម្រង់លក្ខណៈដូចមួកកាស្កេតសម្រាប់ថ្នាក់អគ្គនាយកដែរ ដោយខុសគ្នានៅត្រង់គែមរបស់ក្បាំងមួកគ្មានវ័ណ្ឌពណ៌មាសព័ទ្ធដល់ជើងមួកឡើយ។

១.៣- **ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ** : មានទម្រង់លក្ខណៈដូចមួកកាស្កេតសម្រាប់ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋានដែរ ដោយខុសគ្នានៅលើកណ្តាប់វ័ណ្ឌប៉ានពណ៌បៃតងខ្ចីគ្មានក្បាច់ប៉ាក់ផ្កាភ្ញីទេសពណ៌មាសទេ ហើយនៅលើក្បាំងមួកមានក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងមានប្រវែងមួយភាគបីពីជើងមួក។

១.៤- **ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ** : មានទម្រង់លក្ខណៈដូចមួកកាស្កេតសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរដែរ ដោយខុសគ្នានៅត្រង់ក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងមានប្រវែងពីរភាគបីពីជើងមួក។

១.៥- **ថ្នាក់មន្ត្រី** : មានទម្រង់លក្ខណៈដូចមួកកាស្កេតសម្រាប់ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរដែរ ដោយខុសគ្នានៅលើក្បាំងមួកគ្មានក្បាច់សន្លឹកភ្ញីទេសទម្រង់ស្នែងក្របីឡើយ។

២- មួកសំបុកផលិតពីសាច់ក្រណាត់មានពណ៌ដូចខោនិងអាវដែរ មានកណ្តាប់វល្លិប៉ានជុំវិញរង្វង់ជើងមួកពណ៌បៃតងខ្ចី ហើយផ្នែកខាងលើកណ្តាប់វល្លិចំកណ្តាលផ្នែកមុខមួកមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។ នៅត្រង់កណ្តាប់វល្លិផ្នែកខាងមុខរចនាដោយក្បាច់ប៉ាក់ភ្ញីរូបកណ្តាប់ស្រូវបញ្ឈរកម្ពស់៣៥មិល្លីម៉ែត្រនិងអមដោយក្បាច់ប៉ាក់សន្លឹកភ្ញីទេសពណ៌មាសទំហំទទឹង២០មិល្លីម៉ែត្រព័ទ្ធជុំវិញរហូតដល់ជើងមួកដែលបញ្ចប់ដោយឡេវត្រារូបព្រះរាជសង្ហារពណ៌មាសម្ខាងមួយ។ ហាមមួកដេរដោយសាច់ក្រណាត់ជុំវិញបត់ភ្លើយមួយផ្នែកខាងក្រោយ ហើយផ្នែកខាងមុខនៃក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីមានប្រវែងខុសគ្នាឆ្ពោះទៅរកជើងមួក។

មួកសំបុកត្រូវបានកំណត់ជា៥(ប្រាំ)ថ្នាក់ ដូចខាងក្រោម៖

២.១- **ថ្នាក់អគ្គនាយក** : ក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងដល់ជើងមួក និងគែមខាងមុខរបស់ក្បាំងមួកមានវល្លិទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

២.២- **ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន** : មានទម្រង់លក្ខណៈដូចមួកសំបុកសម្រាប់ថ្នាក់អគ្គនាយកដែរ ដោយខុសគ្នានៅត្រង់គែមខាងមុខរបស់ក្បាំងមួកគ្មានវល្លិពណ៌មាសពទ្ធ័ដល់ជើងមួកឡើយ។

២.៣- **ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ** : មានទម្រង់លក្ខណៈដូចមួកសំបុកសម្រាប់ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋានដែរ ដោយខុសគ្នានៅលើកណ្តាប់វល្លិប៉ានពណ៌បៃតងខ្ចីគ្មានក្បាច់ប៉ាក់ផ្កាភ្ញីទេសពណ៌មាសទេ ហើយនៅលើក្បាំងមួកមានក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងមានប្រវែងមួយភាគបីពីជើងមួក។

២.៤- **ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ** : មានទម្រង់លក្ខណៈដូចមួកសំបុកសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរដែរ ដោយខុសគ្នានៅត្រង់ក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងមានប្រវែងពីរភាគបីពីជើងមួក។

២.៥- **ថ្នាក់មន្ត្រី** : មានទម្រង់លក្ខណៈដូចមួកសំបុកសម្រាប់ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរដែរ ដោយខុសគ្នានៅលើក្បាំងមួកគ្មានក្បាច់សន្លឹកភ្ញីទេសទម្រង់ស្នែងក្របីឡើយ។

៣- មួកកន្តឹបផលិតពីសាច់ក្រណាត់និងមានពណ៌ដូចខោនិងអាវដែរ ផ្នែកខាងមុខមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានរចនាដោយក្បាច់ប៉ាក់ភ្ញីរូបកណ្តាប់ស្រូវបញ្ឈរកម្ពស់៣៥មិល្លីម៉ែត្រ និងអមដោយក្បាច់ប៉ាក់សន្លឹកភ្ញីទេសពណ៌មាសកម្ពស់២០មិល្លីម៉ែត្រព័ទ្ធជុំវិញរហូតដល់ជើងមួកនិងបញ្ចប់ដោយឡេវព្រះរាជសង្ហារពណ៌មាស ហើយផ្នែកខាងមុខនៃក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីមានប្រវែងខុសគ្នាឆ្ពោះទៅរកជើងមួក។

ម្ជុលកន្លឹបត្រូវបានកំណត់ជា៥(ប្រាំ)ថ្នាក់ ដូចខាងក្រោម៖

៣.១- **ថ្នាក់អគ្គនាយក** : ក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងដល់ជើងម្ជុល និងគែមរបស់ក្បាំងម្ជុលមានវ័ណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងម្ជុល។

៣.២- **ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន** : មានទម្រង់លក្ខណៈដូចម្ជុលកន្លឹបសម្រាប់ថ្នាក់អគ្គនាយកដែរដោយខុសគ្នានៅត្រង់គែមរបស់ក្បាំងម្ជុលគ្មានវ័ណ្ឌពណ៌មាសព័ទ្ធដល់ជើងម្ជុលឡើយ។

៣.៣- **ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ** : មានទម្រង់លក្ខណៈដូចម្ជុលកន្លឹបសម្រាប់ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋានដែរ ដោយខុសគ្នានៅលើក្បាំងម្ជុលមានក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងមានប្រវែងមួយភាគបីពីជើងម្ជុល។

៣.៤- **ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ** : មានទម្រង់លក្ខណៈដូចម្ជុលកន្លឹបសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរដែរ ដោយខុសគ្នានៅត្រង់ក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្នែងក្របីអមសងខាងមានប្រវែងពីរភាគបីពីជើងម្ជុល។

៣.៥- **ថ្នាក់មន្ត្រី** : មានទម្រង់លក្ខណៈដូចម្ជុលកន្លឹបសម្រាប់ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរដែរដោយខុសគ្នានៅលើក្បាំងម្ជុលគ្មានក្បាច់សន្លឹកភ្ញីទេសទម្រង់ស្នែងក្របីឡើយ។

គំរូម្ជុលរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ដូចខាងក្រោម៖

ក- ចំពោះបុរស

- ខ្សែក្រវាត់ផលិតពីសរសៃខ្សែនពណ៌ខ្មៅ ក្បាលខ្សែក្រវាត់មានពណ៌មាស មានទទឹង៣៨មិល្លីម៉ែត្រ និងបណ្តោយ៦៥មិល្លីម៉ែត្រ
- ស្បែកជើងជាប្រភេទស្បែកជើងឃ្លុបកខ្លី ផលិតពីស្បែកពណ៌ខ្មៅ និងចងខ្សែ
- ស្រោមជើងមានពណ៌ខ្មៅនិងកវែង។

ខ- ចំពោះនារី

- ខ្សែក្រវាត់មានទម្រង់លក្ខណៈដូចខ្សែក្រវាត់បុរសដែរ
- ស្បែកជើងជាប្រភេទស្បែកជើងឃ្លុបកខ្លីផលិតពីស្បែកពណ៌ខ្មៅនិងកែងទាបមិនលើសពី៣០ មិល្លីម៉ែត្រ
- ស្រោមជើងមានពណ៌ខ្មៅនិងកវែង។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## សញ្ញាសម្គាល់

**មាត្រា៦ .-**

សញ្ញាសម្គាល់ជាស្លាកសញ្ញាកំណត់អត្តសញ្ញាណនៃភ្នាក់ងារអធិការកិច្ចពូជដំណាំ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដៃអាវខាងស្តាំ

តួស្លាកនេះធ្វើពីក្រណាត់ប៉ាក់អណ្តែតមានរាងរង្វង់មូលពីរជាន់ដែលមានទំហំអង្កត់ផ្ចិតរួម៨០មិល្លីម៉ែត្រ ក្នុងនោះរង្វង់ខាងក្នុងមានអង្កត់ផ្ចិតទំហំ៦០មិល្លីម៉ែត្រមានទម្រង់លក្ខណៈជាស្លាកសញ្ញាសម្គាល់របស់អគ្គនាយកដ្ឋានកសិកម្មដែលជាអង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចពូជដំណាំ។ រង្វង់ខាងក្រៅមានកម្រាស់២០មិល្លីម៉ែត្រ ផ្ទៃពណ៌សព័ទ្ធជុំវិញរង្វង់ខាងក្នុង។ ផ្នែកខាងលើត្រង់កណ្តាលនៃកំណាត់រង្វង់មានប៉ាក់អក្សរ **ភ្នាក់ងារអធិការកិច្ចពូជដំណាំ** ដែលរចនារាងកោងផ្កាប់តាមវណ្ឌរង្វង់។ ផ្នែកខាងក្រោមត្រង់កណ្តាលនៃកំណាត់រង្វង់មានប៉ាក់អក្សរជាភាសាអង់គ្លេស **SEED INSPECTION AGENT** ទម្រង់រាងកោងផ្ងារតាមវណ្ឌរង្វង់។ នៅចន្លោះកំណាត់រង្វង់ទាំងពីរនេះមានខ្សែឆ្នូតពីរជាន់ពណ៌បៃតងដែលខណ្ឌចែករវាងភាសាខ្មែរនិងភាសាអង់គ្លេស។

២- ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេងស្តាំ

តួស្លាកសញ្ញានេះធ្វើពីលោហធាតុមានរាងមូលដែលមានអង្កត់ផ្ចិត៣០មិល្លីម៉ែត្រនិងមានទម្រង់លក្ខណៈដូចទាំងស្រុងទៅនឹងស្លាកសញ្ញាសម្គាល់អត្តសញ្ញាណនៃភ្នាក់ងារអធិការកិច្ចពូជដំណាំខាងលើ។

៣- ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរក្រោមគម្របហោប៉ៅអាវខាងស្តាំ

តួស្លាកសញ្ញានេះធ្វើពីលោហធាតុមានរាងសំប៉ែតនិងមានរូបសញ្ញាសម្គាល់អត្តសញ្ញាណនៃភ្នាក់ងារអធិការកិច្ចពូជដំណាំដែលមានអង្កត់ផ្ចិត៤៥មិល្លីម៉ែត្រភ្ជាប់ដោយបន្ទះស្បែកបញ្ឈរសម្រាប់ព្យួរនៅហោប៉ៅអាវខាងស្តាំ។

៤- ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវខាងស្តាំ

តួស្លាកសញ្ញាធ្វើពីជ័រផ្លាស្ទិកពណ៌បៃតងខ្ចីរាងចតុកោណកែងបណ្តោយ១០០មិល្លីម៉ែត្រ ទទឹង២០មិល្លីម៉ែត្រ មានបន្ទាត់វណ្ឌពណ៌សព័ទ្ធជុំវិញជ្រុងទាំងបួន និងមានតួអក្សរពណ៌ស។ តួស្លាកសញ្ញាចែកចេញជាពីរផ្នែកប៉ែកខាងឆ្វេងមានបណ្តោយ២៥មិល្លីម៉ែត្រ នៅចំកណ្តាលមានស្លាកសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំដែលមានអង្កត់ផ្ចិត១៥មីល្លីម៉ែត្រ។ ប៉ែកខាងស្តាំមានបណ្តោយ៧៥មិល្លីម៉ែត្រ ចែកចេញជាពីរជួរបណ្តោយ ដែលជួរខាងលើសរសេរឈ្មោះមន្ត្រីភ្នាក់ងារអធិការកិច្ចពូជដំណាំជាអក្សរខ្មែរដែលមានកម្ពស់អក្សរ៥មិល្លីម៉ែត្រ និងជួរខាងក្រោមសរសេរតួនាទីរបស់មន្ត្រីជាអក្សរខ្មែរដែល មានកម្ពស់អក្សរ៣មិល្លីម៉ែត្រ។

គំរូសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

សញ្ញាសក្តិប្រើសម្រាប់ពាក់លើស្មាអាវទាំងសងខាងរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ ដែលផលិតពីបន្ទះលោហធាតុមានរាងទ្រវែងស្តួចបណ្តោយប្រវែង១៣២មិល្លីម៉ែត្រ មានទទឹងខាងគល់ប្រវែង៥៧មិល្លីម៉ែត្រ និងខាងចុងប្រវែង៤៥មិល្លីម៉ែត្រមានរាងកោងជាមុំទាល នៅផ្នែកខាងចុងនៃបន្ទះសក្តិមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមរាងធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញកម្រាស់៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសពណ៌មាសនៅត្រង់គល់ស៊ុមផ្នែកខាងក្រោមទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងចុងនៃបន្ទះសក្តិក្រោមស៊ុមមានឡេវរូបព្រះរាជសង្ហារពណ៌មាសដែលមានទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ។ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មានសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំដែលមានអង្កត់ផ្ចិតទំហំ២៥មិល្លីម៉ែត្រ។ នៅពីក្រោមសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំប្រវែង២០មិល្លីម៉ែត្រមានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសដែលមានកម្ពស់១៤មិល្លីម៉ែត្រនិងមានចុងជាប់ស៊ុមទាំងសងខាង។

សញ្ញាសក្តិត្រូវបានកំណត់ជា៥(ប្រាំ)ថ្នាក់ ស្របតាមតួនាទីនិងឋានៈរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំដូចខាងក្រោម៖

១- ថ្នាក់អគ្គនាយក

បន្ទះសក្តិសម្រាប់ថ្នាក់អគ្គនាយកមានលក្ខណៈសម្គាល់នៅត្រង់ចន្លោះរវាងចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនិងចម្លាក់ក្បាច់អង្គរភ្ញីទេសពណ៌មាសមានខ្សែសយពណ៌មាស២ជាន់ចំនួន២ស្របគ្នា ដែលខ្សែសយនីមួយៗមានកម្រាស់២មិល្លីម៉ែត្រ ហើយនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ **អធិការកិច្ចពូជដំណាំ** ពណ៌មាស។

២- ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន

បន្ទះសក្តិសម្រាប់ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋានមានទម្រង់លក្ខណៈដូចបន្ទះសក្តិសម្រាប់ថ្នាក់អគ្គនាយកដែរ ដោយខុសគ្នានៅត្រង់ខ្សែសយពណ៌មាសមាន១ជាន់ចំនួន២ស្របគ្នា។

៣- ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ

បន្ទះសក្តិសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរមានទម្រង់លក្ខណៈដូចបន្ទះសក្តិសម្រាប់ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋានដែរ ដោយខុសគ្នានៅត្រង់ខ្សែសយ២ជាន់ចំនួន២ស្របគ្នាមានពណ៌ប្រាក់ ដែលខ្សែសយនីមួយៗមានកម្រាស់២មិល្លីម៉ែត្រ ហើយនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ **អធិការកិច្ចពូជដំណាំ** ពណ៌ប្រាក់។

៤- ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ

បន្ទះសក្តិសម្រាប់ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ មានទម្រង់លក្ខណៈដូចបន្ទះសក្តិសម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរដែរ ដោយខុសគ្នានៅត្រង់ខ្សែសយមាន១ជាន់ចំនួន២ស្របគ្នាពណ៌ប្រាក់ដែលខ្សែសយនីមួយៗមានកម្រាស់២មិល្លីម៉ែត្រ ហើយនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ **អធិការកិច្ចពូជដំណាំ** ពណ៌ប្រាក់។

៥- ថ្នាក់មន្ត្រី

បន្ទះសក្តិសម្រាប់ថ្នាក់មន្ត្រីមានទម្រង់លក្ខណៈដូចបន្ទះសក្តិសម្រាប់ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរដែរ ដោយខុសគ្នានៅត្រង់ចន្លោះរវាងចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្ស និងចម្លាក់ក្បាច់អង្គរភ្ញីទេស មិនមានខ្សែសយតែមានត្រឹមចារឹកអក្សរ **អធិការកិច្ចពូជដំណាំ** ពណ៌ប្រាក់។

គំរូសញ្ញាសក្តិរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការផ្តល់និងការប្រើប្រាស់ឯកសណ្ឋាននិងសញ្ញាសម្គាល់

**មាត្រា៨ .-**

ឯកសណ្ឋាននិងសញ្ញាសម្គាល់ដូចបានកំណត់ក្នុងអនុក្រឹត្យនេះត្រូវបានផ្តល់ជូនភ្នាក់ងារអធិការកិច្ចពូជដំណាំក្នុងមួយនាក់ទទួលបានចំនួន២(ពីរ) សម្រាប់ប្រើក្នុងរយៈពេល១(មួយ)ឆ្នាំ ស្របតាមទំហំការងារនិងថវិកាជាតិប្រចាំឆ្នាំ ដែលត្រូវធ្វើវិភាជន៍សម្រាប់អង្គភាព។

គំរូឈុតឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

**មាត្រា៩ .-**

ឯកសណ្ឋាននិងសញ្ញាសម្គាល់នេះត្រូវបានអនុញ្ញាតឱ្យភ្នាក់ងារអធិការកិច្ចពូជដំណាំដែលបម្រើការងារនៅអគ្គនាយកដ្ឋានកសិកម្ម នាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រើសម្រាប់៖

- បំពេញបេសកកម្មធ្វើអធិការកិច្ចពូជដំណាំ ដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ចូលរួមក្នុងសវនាការនៅតុលាការ
- ចូលរួមពិធីផ្លូវការផ្សេងៗ រួមមានកិច្ចប្រជុំ សន្និបាត សន្និសីទ ពិធីបុណ្យជាតិ ឬពិធីផ្លូវការផ្សេងទៀតនៅថ្នាក់ជាតិឬថ្នាក់ក្រោមជាតិ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១០ .-**

ជនណាដែលក្លែងឯកសណ្ឋាននិងសញ្ញាសម្គាល់ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៥ ១៥កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១៧៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០២០
ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ
គំរូសម្លៀកបំពាក់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

### គំរូអាវដៃវែងសម្រាប់ពិធីការ

**ក.ចំពោះបុរស**



**ខ.ចំពោះនារី**



## គំរូអាវដៃវែងសម្រាប់ការងារអធិការកិច្ច

### ក.ចំពោះបុរស



### ខ.ចំពោះនារី



## គំរូអាវដៃខ្លីសម្រាប់ការងារអធិការកិច្ច

**ក.ចំពោះបុរស**



**ខ.ចំពោះនារី**



## គំរូខោជើងវែង

**ក.ចំពោះបុរស**



**ខ.ចំពោះនារី**



គំរូសំពត់សម្រាប់នារី



## ឧបសម្ព័ន្ធទី២

## នៃអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

## ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

## គំរូម្ហួករបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

### គំរូម្ហួកកាស្កេតសម្រាប់ពិធីការចំពោះបុរស

| | |
|---|---|
|  | ថ្នាក់អគ្គនាយក |
|  | ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន |
|  | ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធាន ការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ |
|  | ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ |
|  | ថ្នាក់មន្ត្រី |

## គំរូមួកសំបុកសម្រាប់ពិធីការចំពោះនារី

| | |
|---|---|
|  | ថ្នាក់អគ្គនាយក |
|  | ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន |
|  | ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ |
|  | ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ |
|  | ថ្នាក់មន្ត្រី |

## គំរូមួកកន្តឹបសម្រាប់ការងារអធិការកិច្ចចំពោះបុរសនិងនារី

| | |
|---|---|
|  | ថ្នាក់អគ្គនាយក |
|  | ថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន |
|  | ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធាន ការិយាល័យថ្នាក់កណ្តាល ប្រធាននិងអនុប្រធានមន្ទីរ |
|  | ថ្នាក់ប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ |
|  | ថ្នាក់មន្ត្រី |

## ឧបសម្ព័ន្ធទី៣

**នៃអនុក្រឹត្យលេខ ១៧៤អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០**

**ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ**

**គំរូខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើងរបស់ភ្នាក់ងារអធិការកិច្ចពុជដំណាំ**

| | |
|---|---|
|  | ខ្សែក្រវាត់ចំពោះបុរស |
|  | ខ្សែក្រវាត់ចំពោះនារី |
|  | ស្បែកជើងចំពោះបុរស |
|  | ស្បែកជើងចំពោះនារី |
|  | ស្រោមជើង |

**ឧបសម្ព័ន្ធទី៤**
**នៃអនុក្រឹត្យលេខ ១៧៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២០**
**ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ**
**គំរូសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ**

| | |
|---|---|
|  | ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដៃអាវខាងស្តាំ |
|  | ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេងស្តាំ |
|  | ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរក្រោមគម្រប‌ហោប៉ៅអាវស្តាំ |
|  | ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីភ្នាក់ងារអធិការកិច្ចពូជ ដំណាំសម្រាប់ពាក់លើគម្របហោប៉ៅអាវខាងស្តាំ |

x

## ឧបសម្ព័ន្ធទី៥

## នៃអនុក្រឹត្យលេខ ១៧៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២០

## ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

## គំរូសញ្ញាសក្តិរបស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ




គំរូសញ្ញាសក្តិថ្នាក់អគ្គនាយក




គំរូសញ្ញាសក្តិថ្នាក់អគ្គនាយករងនិងប្រធាននាយកដ្ឋាន




គំរូសញ្ញាសក្តិថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យថ្នាក់កណ្តាល
ប្រធាននិងអនុប្រធានមន្ទីរ




គំរូសញ្ញាសក្តិប្រធាននិងអនុប្រធានការិយាល័យនៃមន្ទីរ




គំរូសញ្ញាសក្តិថ្នាក់មន្ត្រី

## ឧបសម្ព័ន្ធទី៦

នៃអនុក្រឹត្យលេខ ១៧៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២០

ស្តីពីឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

### គំរូឈុតឯកសណ្ឋាននិងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

គំរូឈុតឯកសណ្ឋានសម្រាប់ពិធីការ



គំរូឈុតឯកសណ្ឋានដៃវែងសម្រាប់ការងារអធិការកិច្ច



គំរូឈុតឯកសណ្ឋានដៃខ្លីសម្រាប់ការងារអធិការកិច្ច

